ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដែលសរសេរជាអក្សរកាត់ថា **គ.រ.ឌ.** ដើម្បីធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបំពេញមុខងារជាសេនាធិការជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល (**ក.ស.ឌ.**) លើការងារបច្ចេកទេស និងគោលនយោបាយនៅក្នុងការដឹកនាំ សម្របសម្រួល និងជំរុញការកសាងរដ្ឋាភិបាលឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.រ.ឌ.

**មាត្រា២ .-**

**គ.រ.ឌ.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំនិងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ និងទិសដៅ តាមសកម្មភាពអាទិភាពនៃការកសាងរដ្ឋាភិបាលឌីជីថល ដើម្បីដាក់ជូន **ក.ស.ឌ.** ពិនិត្យនិងសម្រេច
- រៀបចំ សិក្សា ស្រាវជ្រាវ និងជំរុញការផ្សព្វផ្សាយអំពីរដ្ឋាភិបាលឌីជីថល តាមរយៈសិក្ខាសាលា កម្មវិធីផ្សព្វផ្សាយ ទស្សនកិច្ចសិក្សា និងការផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធនឹងរដ្ឋាភិបាលឌីជីថល
- ពិនិត្យ សិក្សា លើកសំណើ និងផ្តល់យោបល់ជូន **ក.ស.ឌ.** លើការរៀបចំ ការកែសម្រួល និង/ឬការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការកសាងរដ្ឋាភិបាលឌីជីថល
- ជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងកម្មវិធី គម្រោង និងផែនការកសាងរដ្ឋាភិបាលឌីជីថល ដោយមានយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព
- រៀបចំនិងជំរុញការអនុវត្តស្តង់ដារបច្ចេកទេសសម្រាប់ការកសាងរដ្ឋាភិបាលឌីជីថលដើម្បីជានាអន្តរប្រតិបត្តិការនៃប្រព័ន្ធព័ត៌មានឌីជីថលរបស់ក្រសួង ស្ថាប័ន និងវិស័យឯកជន
- សហការ រៀបចំ និងជំរុញការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់ដំណើរប្រព្រឹត្តទៅនៃក្រសួងស្ថាប័ន ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធព័ត៌មានឌីជីថល សម្រាប់អភិបាលកិច្ចនិងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល
- ដឹកនាំ សម្របសម្រួល សហការ រៀបចំ និងជំរុញការអនុវត្តផែនការកសាងរដ្ឋាភិបាលឌីជីថល ដែលមានវិសាលភាពគ្របដណ្តប់លើអភិបាលកិច្ចនិងសេវាសាធារណៈ តាមរយៈការធ្វើសុខដុមនីយកម្ម ការកំណត់អាទិភាពនៃគម្រោងនានា និងការជំរុញប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ស្របតាមកម្រិតឧត្តមានុពលនិងស្តង់ដារបច្ចេកទេស
- ជំរុញការរៀបចំទិន្នន័យគោល ( Base Registry ) និងការចែករំលែកទិន្នន័យរវាងក្រសួងស្ថាប័ន និងវិស័យឯកជន សំដៅជំរុញល្បឿននៃការកសាងមូលដ្ឋាន ការចាប់យក និងការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល
- រៀបចំផែនការប្រចាំឆ្នាំ រយៈពេលមធ្យម និងវែង ស្របតាមសកម្មភាពអាទិភាពនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ដើម្បីលើកសំណើជូន **ក.ស.ឌ.** ពិនិត្យនិងសម្រេច
- សម្របសម្រួល ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើគម្រោងរដ្ឋាភិបាលឌីជីថល ដើម្បីបន្តនីតិវិធីអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យនិងសិក្សាលើគម្រោងបរិវត្តកម្មរដ្ឋាភិបាលឌីជីថលប្រចាំឆ្នាំរយៈពេលមធ្យម និងវែង ដែលស្នើដោយក្រសួងស្ថាប័ន ស្របតាមផែនការសកម្មភាពអាទិភាពនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ដើម្បីលើកសំណើជូន **ក.ស.ឌ.** ពិនិត្យនិងសម្រេច
- បង្កើតកិច្ចសហប្រតិបត្តិការក្នុងប្រទេសនិងអន្តរជាតិ លើការកសាងរដ្ឋាភិបាលឌីជីថល
- កៀរគរធនធានហិរញ្ញវត្ថុ ធនធានបច្ចេកទេស និងមូលធនមនុស្សឌីជីថល ដើម្បីកសាងរដ្ឋាភិបាលឌីជីថល
- ជំរុញ សម្របសម្រួល និងគាំទ្រការចូលរួមកសាងរដ្ឋាភិបាលឌីជីថលពីគ្រប់មជ្ឈដ្ឋាន ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល
- ជំរុញការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ ស្តង់ដា កម្មវិធី គម្រោង និងផែនការកសាងរដ្ឋាភិបាល

ឌីជីថល ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ព្រមទាំងកែសម្រួលសកម្មភាពអាទិភាពតាមការចាំបាច់ និងរៀបចំរបាយការណ៍ជូន **គ.ស.ឌ.** ពិនិត្យនិងសម្រេច

- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ស.ឌ.**។

## ជំពូកទី៣
## សមាសភាពរបស់ គ.រ.ឌ.

**មាត្រា៣ .-**

**គ.រ.ឌ.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |

- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង ១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ១រូប សមាជិក
- ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ១រូប សមាជិក
- តំណាងអាជ្ញាធរសវនកម្មជាតិ ១រូប សមាជិក
- តំណាងអង្គភាពប្រឆាំងអំពើពុករលួយ ១រូប សមាជិក
- អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប សមាជិក
- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១រូប សមាជិក
- ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមាជិក
- ប្រធានបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានទូរគមនាគមន៍ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** សមាជិកអចិន្ត្រៃយ៍។

**គ.រ.ឌ.** អាចមានសមាសភាពបន្ថែមជាតំណាងក្រសួង ស្ថាប័នផ្សេងទៀត តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.រ.ឌ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.រ.ឌ.

**មាត្រា៤ .-**

**គ.រ.ឌ.** ត្រូវប្រជុំរៀងរាល់ ៣ (បី) ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន **គ.រ.ឌ.** អាចកោះប្រជុំជាវិសាមញ្ញបាន។ ក្នុងករណីអវត្តមាន ប្រធាន **គ.រ.ឌ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយ ដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **គ.រ.ឌ.** ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់ថ្នាក់ដឹកនាំដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមកិច្ចប្រជុំនិងសម្រេចជំនួស។

**មាត្រា៥ .-**

ប្រធាន **គ.រ.ឌ.** ឬអនុប្រធានដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.រ.ឌ.** តាមការចាំបាច់។

**មាត្រា៦ .-**

**គ.រ.ឌ.** មានក្រុមការងារបច្ចេកទេសអន្តរក្រសួងជាសេនាធិការបច្ចេកទេស ដឹកនាំដោយតំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានសមាសភាពចូលរួមជាតំណាងពីក្រសួង ស្ថាប័ន។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងមានតួនាទីនិងភារកិច្ចទទួលខុសត្រូវលើការងារបច្ចេកទេស និងដំណើរការគម្រោងការអនុវត្តនិងការវាយតម្លៃគម្រោង និងការងារសន្តិសុខឌីជីថល។

សមាសភាពរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.រ.ឌ.**។

**គ.រ.ឌ.** អាចបង្កើតក្រុមការងារបច្ចេកទេសចំពោះកិច្ចដោយសេចក្តីសម្រេចរបស់ប្រធាន **គ.រ.ឌ.** តាមការចាំបាច់។

**មាត្រា៧ .-**

**គ.រ.ឌ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានតួនាទីនិងភារកិច្ចទទួលខុសត្រូវលើការងារបច្ចេកទេសនិងរដ្ឋបាលជូន **គ.រ.ឌ.** ដូចជា កិច្ចការរដ្ឋបាល ការរៀបចំរបាយការណ៍ ការស្រាវជ្រាវគោលនយោបាយនិងច្បាប់ ការសិក្សានិងអភិវឌ្ឍគម្រោង ការជំរុញបរិវត្តកម្មរដ្ឋាភិបាលឌីជីថល ការរៀបចំកម្មវិធីអភិវឌ្ឍន៍ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការត្រួតពិនិត្យ ការតាមដាន ការវាយតម្លៃ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងបំពេញតួនាទីនិងភារកិច្ចដទៃទៀតតាមការប្រគល់ជូនពីប្រធាន **គ.រ.ឌ.**។

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានគោលនយោបាយនិងនីតិកម្ម
- នាយកដ្ឋានសិក្សាគម្រោងនិងកម្មវិធីអភិវឌ្ឍន៍
- នាយកដ្ឋានបរិវត្តកម្មរដ្ឋាភិបាលឌីជីថល
- នាយកដ្ឋានត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

នាយកដ្ឋាននីមួយៗ មានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងជាប្រធាន **គ.រ.ឌ.**។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

នាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការងារផែនការ ទទួលប្រើប្រាស់ ចាត់ចែង ថែទាំ កៀរគរ តាមដាន ត្រួតពិនិត្យ វាយតម្លៃ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធរដ្ឋបាល ហិរញ្ញវត្ថុ ថវិកា សារពើភណ្ឌ ធនធានមនុស្ស លទ្ធកម្ម ឯកសារ កិច្ចការទូទៅ ការបណ្តុះបណ្តាល ទំនាក់ទំនងសាធារណៈនិងអន្តរជាតិ និងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.**។

**មាត្រា១០ .-**

នាយកដ្ឋានគោលនយោបាយនិងនីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការងារដឹកនាំ សហការ សម្របសម្រួល ផ្តួចផ្តើម កំណត់កម្មវត្ថុ វិភាគ ពិនិត្យ លើកសំណើផ្តល់យោបល់ រៀបចំ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការស្រាវជ្រាវគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ការផ្សព្វផ្សាយ និងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការកសាងរដ្ឋាភិបាលឌីជីថល។

**មាត្រា១១ .-**

នាយកដ្ឋានសិក្សាគម្រោងនិងកម្មវិធីអភិវឌ្ឍន៍ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការងារដឹកនាំ សហការ សម្របសម្រួល ពិនិត្យ លើកយោបល់ ផ្តួចផ្តើម ជំរុញ ស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការសិក្សាពីសមិទ្ធលទ្ធភាពគម្រោង ផលប៉ះពាល់ដល់សេដ្ឋកិច្ចនិងសង្គម ផែនការមេនិងផែនការសកម្មភាពរដ្ឋាភិបាលឌីជីថល ផែនការមេក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការវិនិយោគប្រចាំឆ្នាំ ក្របខណ្ឌវាយតម្លៃគម្រោង

និងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** សំដៅកសាងរដ្ឋាភិបាលឌីជីថល។

**មាត្រា១២ .-**

នាយកដ្ឋានបរិវត្តកម្មរដ្ឋាភិបាលឌីជីថល បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការងារដឹកនាំ សហការ សម្របសម្រួល ពិនិត្យ លើកយោបល់ ផ្តួចផ្តើម ជំរុញ ស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការរៀបចំក្របខណ្ឌអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋាភិបាលឌីជីថល ស្តង់ដា គោលការណ៍ លំហូរការងាររដ្ឋបាល អន្តរប្រតិបត្តិការ និងការគ្រប់គ្រងគម្រោង ព្រមទាំងការជំរុញនវានុវត្តន៍និងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ប្រព័ន្ធឌីជីថលរួម ការសម្របសម្រួលជាមួយជនបង្គោលទទួលបន្ទុកបរិវត្តកម្មឌីជីថលតាមក្រសួង ស្ថាប័ន និងការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.**។

**មាត្រា១៣ .-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** លើការងារសហការ សម្របសម្រួល ពិនិត្យ រៀបចំ ចែករំលែក ជំរុញ គ្រប់គ្រង និងអភិវឌ្ឍ ពាក់ព័ន្ធការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង ផែនការ របាយការណ៍ សូចនាករ ទិន្នន័យ ពាក់ព័ន្ធនឹងការកសាងរដ្ឋាភិបាលឌីជីថល តាមការណែនាំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.**។

**មាត្រា១៤ .-**

អគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ដឹកនាំដោយអគ្គលេខាធិការ ១ (មួយ) រូប អមដោយអគ្គលេខាធិការរងមួយចំនួន ដែលត្រូវមានឋានៈចាប់ពីអគ្គនាយកឡើងនិងតែងតាំងដោយព្រះរាជក្រឹត្យ។

នាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ប្រធាននាយកដ្ឋាននីមួយៗនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ត្រូវតែងតាំង ឬផ្លាស់ប្តូរភារកិច្ចដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាប្រធាន **គ.រ.ឌ.**។ ការតែងតាំងនិងការផ្លាស់ប្តូរភារកិច្ចមន្ត្រី ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាប្រធាន **គ.រ.ឌ.**។

**មាត្រា១៥ .-**

មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** រួមមានមន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនិងមន្ត្រីជាប់កិច្ចសន្យា។

**មាត្រា១៦ .-**

អគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** អាចមានអ្នកជំនាញការជាតិនិង/ឬអ្នកជំនាញការអន្តរជាតិមួយចំនួនសម្រាប់ជួយការងារតាមតម្រូវការជាក់ស្តែង។ អ្នកជំនាញការនៃអគ្គលេខាធិការដ្ឋាន **គ.រ.ឌ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.រ.ឌ.**។

**មាត្រា១៧ .-**

**គ.រ.ឌ.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ស.ឌ.** សម្រាប់បំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.វ.ឧ.

**មាត្រា១៨ .-**

ការចំណាយសម្រាប់ដំណើរការការងាររបស់ **គ.វ.ឧ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិកាកម្មវិធីរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**គ.វ.ឧ.** មានសិទ្ធិទទួល គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងថវិកាដៃគូអភិវឌ្ឍន៍ ព្រមទាំងធនធានជាថវិកា និងទ្រព្យសម្បត្តិស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ....៨១........ អនក្រ.បក ចុះថ្ងៃទី.....១៩.....ខែ.....មេសា.......ឆ្នាំ២០២២**

**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល (គ.រ.ឌ.)**

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.រ.ឌ.**

